# ព្រះរាជក្រម

នស/រកម/១០០៤/០០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់លិខិតលេខ ២៥៦រស. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤ របស់រដ្ឋសភា ស្តីពីសំណើសុំធ្វើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សារាជសម្បត្តិ

-បានទ្រង់យល់សេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅ
# នៃក្រុមប្រឹក្សារាជសម្បត្តិ

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដើម្បីជ្រើសរើសព្រះមហាក្សត្រ និងធានានូវដំណើរការជាប្រក្រតីនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-**

ការជ្រើសរើសព្រះមហាក្សត្រថ្មីជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ។

# ជំពូកទី ២
# ការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៣ .-**

អនុលោមតាមមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ មានដូចខាងក្រោម :

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធានទី ១ |
| ៣-នាយករដ្ឋមន្ត្រី | អនុប្រធានទី ២ |
| ៤-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | សមាជិក |
| ៥-សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ | សមាជិក |
| ៦-អនុប្រធានទី ១ ព្រឹទ្ធសភា | សមាជិក |
| ៧-អនុប្រធានទី ១ រដ្ឋសភា | សមាជិក |
| ៨-អនុប្រធានទី ២ ព្រឹទ្ធសភា | សមាជិក |
| ៩-អនុប្រធានទី ២ រដ្ឋសភា | សមាជិក |

មាត្រា ៤ .-

ប្រធានក្រុមប្រឹក្សារាជសម្បត្តិដឹកនាំអង្គប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ទទួលអាណត្តិ សេចក្ដីសម្រេចនានា ដែលក្រុមប្រឹក្សារាជសម្បត្តិបានអនុម័ត ចាត់ចែងនិងរៀបចំការអនុវត្តន៍ច្បាប់ទាំងឡាយដែលទាក់ទងនឹងការគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រ ។

មាត្រា ៥.-

ក្នុងករណីដែលប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ឬ ពុំមានលទ្ធភាពបំពេញមុខងារបានដោយមានមូលហេតុច្បាស់លាស់ អនុប្រធានក្រុមប្រឹក្សារាជសម្បត្តិត្រូវទទួលភារកិច្ចចាត់ចែងការជំនួស ។

មាត្រា ៦ .-

ក្នុងករណីដែលប្រធាននិងអនុប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមានឬពុំមានលទ្ធភាពបំពេញមុខងារ បានដោយមានមូលហេតុច្បាស់លាស់ ក្រុមប្រឹក្សារាជសម្បត្តិនឹងត្រូវដឹកនាំដោយ :

-អនុប្រធានទី ១ ព្រឹទ្ធសភា ប្រធាន

-អនុប្រធានទី ១ រដ្ឋសភា អនុប្រធាន

មាត្រា ៧ .-

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងត្រូវទទួលបន្ទុករៀបចំទីកន្លែងប្រជុំ កន្លែងធ្វើការនិងធ្វើកំណត់ហេតុរបស់ក្រុមប្រឹក្សារាជសម្បត្តិ បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

កំណត់ហេតុនិងឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវរក្សាទុកក្នុងក្រសួងព្រះបរមរាជវាំង ហើយមិនត្រូវធ្វើឱ្យខូចខាតឬខ្ចាត់ខ្ចាយទៅក្រៅឡើយ ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៨ .-**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ សមាជិកបីរូបយ៉ាងតិច អាចលើកសំណើសុំអោយកោះប្រជុំបាន ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិចាត់ទុកជាបានការ លុះត្រាតែមានសមាជិកប្រាំរូបយ៉ាងតិចឡើងទៅចូលរួមប្រជុំ ។ ការពិភាក្សានៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវទុកជាការសម្ងាត់ ។

**មាត្រា ៩.-**

ការអនុម័តរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវយកតាមមតិភាគច្រើនដាច់ខាតគឺប្រាំសម្លេងឡើង តាមរយៈការបោះឆ្នោតដោយសម្ងាត់ ។

**មាត្រា ១០.-**

ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ ក្រោយពីពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ឬ ចូលនិវត្តន៍ ឬដាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវជ្រើសរើសព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១១ .-**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជ-វង្សានុវង្សខ្មែរណាដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ ហើយដែលក្រុមប្រឹក្សារាជសម្បត្តិយល់ឃើញថាមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបម្រើប្រជារាស្ត្រប្រជាជាតិនិងមាតុភូមិ ។

**មាត្រា ១២.-**

សមាជិកក្រុមប្រឹក្សារាជសម្បត្តិ ចាប់ពីបីរូបឡើងអាច ឧទ្ទេសនាមបេក្ខជនព្រះមហាក្សត្រថ្មីមួយអង្គបាន ។ សមាជិកក្រុមប្រឹក្សារាជសម្បត្តិមួយរូប មានសិទ្ធិឧទ្ទេសនាមបានតែបេក្ខជនមួយអង្គប៉ុណ្ណោះ ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី ត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ។

**មាត្រា ១៤.-**

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រថ្មី ទ្រង់ថ្វាយសច្ចាប្រណិធានដូចមានចែងក្នុងឧបសម្ព័ន្ធ ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សារាជសម្បត្តិចេញសេចក្តីសម្រេច ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១៥.-**

ព្រះរាជពិធីអភិសេកព្រះមហាក្សត្រថ្មីតាមប្រពៃណីទំនៀមទម្លាប់នៃព្រះរាជវង្សានុវង្សខ្មែរអាចប្រព្រឹត្តទៅមុនពេលទ្រង់ថ្វាយសច្ចាប្រណិធាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ក្នុងករណីកាលៈទេសៈមិនអនុគ្រោះ ព្រះរាជពិធីអភិសេកនេះអាចនឹងលើកទៅធ្វើនៅក្រោយពេលប្រារព្ធព្រះរាជពិធីបុណ្យឈាបនកិច្ចថ្វាយព្រះសពព្រះមហាក្សត្របាន ។

## ជំពូកទី ៤

## បទប្បញ្ញត្តិពិសេស

**មាត្រា ១៦.-**

ព្រះមហាក្សត្រដែលទ្រង់បានយាងចូលនិវត្តន៍ ឬដាក់រាជ្យ និងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញ និងមិនអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គនៅគ្រងរាជសម្បត្តិ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

៣រល.០៤១០.៣០៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

បានយកសេចក្តីជម្រាបជូនសម្តេចប្រមុខរដ្ឋស្តីទី
ដើម្បីសុំហត្ថលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខៈ ៧៣៩ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់